ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ១៦៧៤ ទស.ពា

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១៧

# រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សូមបញ្ជាក់ថា :

ការីទេសចរណ៍/ភ្នាក់ងារទេសចរណ៍មួយត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្មទេសចរណ៍ពេញលក្ខណៈច្បាប់តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ការីទេសចរណ៍ : រ៉ូតាស (ខេមបូឌា) ត្រាវែល ឯ.ក
: RUTAS (CAMBODIA) TRAVEL COMPANY LIMITED

២- អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co-000២៤៥៦៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧

៣- លិខិតធានារបស់ធនាគារ : ៩៤៣-០២/៥៩៦៧/២០១៧ លើកទី០១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧

សុពលភាពអាជ្ញាបណ្ណទេសចរណ៍ : ០៨-០៧-២០១៧ ដល់ ០៧-០៧-២០១៨

ឆ្នាំបង្កើតការីទេសចរណ៍ : ២០១៧

៤- ឈ្មោះម្ចាស់អាជ្ញាបណ្ណ ឬ អ្នកគ្រប់គ្រង : លោក **ទូច ហាក់**
: Mr. TOUCH HAK ( ខ្មែរ )

៥- ទីស្នាក់ការកណ្តាលការីទេសចរណ៍ : រាជធានីភ្នំពេញ

- អាស័យដ្ឋាន : ផ្ទះលេខ៤២P១៨ ផ្លូវលេខ៦៦៤ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ
- ទូរស័ព្ទ-ទូរសារ-អ៊ីមែល : ០៧៧ ៨៩៧ ៥៦៧ seanghak@gmail.com

៦- ទីស្នាក់ការសាខាការីទេសចរណ៍ : គ្មាន

៧- ប្រភេទអាជីវកម្ម :
- ទទួលទេសចរចូលមកទស្សនាក្នុងប្រទេស : អាស៊ី និងអឺរ៉ុប
- នាំទេសចរទៅក្រៅប្រទេស : គ្មាន
- រៀបចំដំណើរកម្សាន្តក្នុងស្រុក : គ្មាន
- ភ្នាក់ងារទេសចរណ៍ : គ្មាន
- បុគ្គលិកសរុបចំនួន:ខ្មែរប្រុស១នាក់/បរទេស គ្មាន ខ្មែរស្រី១នាក់/បរទេស គ្មាន
- មធ្យោបាយដឹកជញ្ជូនទេសចរណ៍ រថយន្ត : គ្មាន កាណូត : គ្មាន

ពេលដំណើរការប្រកបអាជីវកម្មការីទេសចរណ៍/ភ្នាក់ងារទេសចរណ៍ត្រូវគោរពតាម និងអនុវត្តឱ្យបានម៉ឺងម៉ាត់តាមបទប្បញ្ញត្តិនានារបស់ក្រសួងទេសចរណ៍ ច្បាប់ស្តីពីទេសចរណ៍ និងច្បាប់ផ្សេងៗទៀតរបស់រដ្ឋ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ឌិត ចន្ថា

ចម្លងជូន :
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានពន្ធដារ)
- សាលារាជធានីភ្នំពេញ
" ដើម្បីជូនជ្រាប "
- មន្ទីរទេសចរណ៍រាជធានីភ្នំពេញ " ដើម្បីមុខការ "
- ឯកសារ-កាលប្បវត្តិ

ផ្ទះលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ១២៣៤ តស៊ណ.អប

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១៧

# ជម្រាបជូន

លោក **ឆ្វច ហាក់ ម្ចាស់អាជ្ញាបណ្ណទេសចរណ៍**

**រ៉ូតាស (ខេមបូឌា) ត្រាវែល ឯ.ក RUTAS (CAMBODIA) TRAVEL COMPANY LIMITED**

**កម្មវត្ថុ** : ការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មការីទេសចរណ៍ **រ៉ូតាស (ខេមបូឌា) ត្រាវែល ឯ.ក**។

**យោង** :
- ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- ប្រកាសលេខ០៤១ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍របស់ក្រសួងទេសចរណ៍
- សំណើសុំអនុញ្ញាតច្បាប់ប្រកបអាជីវកម្មការីទេសចរណ៍របស់លោក **ឆ្វច ហាក់** ជាប្រធានការីទេសចរណ៍ RUTAS (CAMBODIA) TRAVEL COMPANY LIMITED ដែលមានទីតាំងស្ថិតនៅផ្ទះលេខ ៤២P១៨ ផ្លូវលេខ២៦៤ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ និងកិច្ចសន្យា គោរពច្បាប់រដ្ឋ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧
- លិខិតលេខMOC-៥៧២៤៤៧៩៦៧ពណ.ចបព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងពាណិជ្ជកម្ម
- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មភ្នាក់ងារទេសចរណ៍ **រ៉ូតាស (ខេមបូឌា) ត្រាវែល ឯ.ក**: Co-000២៤៥៦៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងពាណិជ្ជកម្ម
- លិខិតធានាអាជីវកម្មលេខ៩៤៣-០២/៥៩៦៣/២០១៧ លើកទី០១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា ស្មើទឹកប្រាក់ចំនួន ៥០០០ ដុល្លារអាមេរិក
- កិច្ចសន្យាជួលទីស្នាក់ការ លេខ ១៦៥/១៧ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០១០០២៩៨១៧ ផុតកំណត់ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៦។

ក្រសួងទេសចរណ៍ឯកភាពជាគោលការណ៍ផ្ដល់ជូនការីទេសចរណ៍: **រ៉ូតាស (ខេមបូឌា) ត្រាវែល ឯ.ក**

អាជ្ញាបណ្ណប្រកបអាជីវកម្មការីទេសចរណ៍ មានទីស្នាក់ការកណ្ដាលនៅរាជធានីភ្នំពេញ

ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ត្រូវមានកាតព្វកិច្ចដូចខាងក្រោម ៖

១- ម្ចាស់អាជ្ញាបណ្ណត្រូវតែដាក់ពាក្យសុំបន្តអាជ្ញាបណ្ណឱ្យបាន ៣០ (សាមសិប)ថ្ងៃ យ៉ាងតិចមុនថ្ងៃផុតកំណត់សុពលភាពអាជ្ញាបណ្ណ ដោយភ្ជាប់មកជាមួយនូវប្រាក់កម្រៃអាជ្ញាបណ្ណ ព្រមទាំងឯកសារ និងព័ត៌មានផ្សេងៗ ដែលបានកំណត់នៅក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

២- ក្នុងករណីកំពុងធ្វើអាជីវកម្ម បើមានការផ្ទេរ ឬលក់អាជ្ញាបណ្ណទេសចរណ៍ ឬប្ដូរនាមករណ៍ ឬប្ដូរទីស្នាក់ការ ត្រូវជូនដំណឹងមកក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានមុនយ៉ាងតិច ៣០(សាមសិប)ថ្ងៃ។

៣- មុននឹងបើក ឬបិទអាជីវកម្មប្រតិបត្តិករទេសចរណ៍ត្រូវជូនដំណឹងមកក្រសួងទេសចរណ៍ឱ្យបាន ៣០ (សាមសិប) ថ្ងៃយ៉ាងតិច។

៤- ត្រូវធានាមិនឱ្យមានការប៉ះពាល់ដល់ សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ បរិស្ថាន សុវត្ថិភាព និងចូលរួមការពារប្រយោជន៍ជាតិ និងប្រយោជន៍ទេសចរ និងចូលរួមចំណែកនៅក្នុងការថែរក្សាធនធានធម្មជាតិមិនបំពុល ឬមិនបំផ្លាញបរិស្ថាន ការពារ និងអភិរក្ស មរតកវប្បធម៌ សិល្បៈ ប្រពៃណី ទំនៀមទម្លាប់របស់ប្រជាពលរដ្ឋខ្មែរក្នុងរាល់សកម្មភាពទេសចរណ៍របស់ខ្លួន។

៥- ផ្តល់ជូនក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានទាន់ពេលវេលានូវស្ថិតិនិងព័ត៌មាន ផ្សេងៗ ដែលទាក់ទងនឹងអាជីវកម្មទេសចរណ៍តាមការស្នើសុំ និងការតម្រូវដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

៦- ត្រូវដាក់តាំងអាជ្ញាបណ្ណទេសចរណ៍នៅកន្លែងទទួលភ្ញៀវដែលងាយមើលឃើញច្បាស់ក្នុងទីបរិវេណធ្វើអាជីវកម្មរបស់អ្នកទទួលអាជ្ញាបណ្ណ។

៧- ផ្តល់ដល់ទេសចរនូវព័ត៌មានពិតច្បាស់លាស់ និងទទួលខុសត្រូវផ្តល់សេវាកម្ម ដូចដែលបានសន្យាព្រមទាំងមានវិធានការសមស្របដើម្បីថែទាំទ្រព្យសម្បត្តិ ការពារសន្តិសុខ និងសុវត្ថិភាពដល់ទេសចរក្នុងពេលដែលទេសចរស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។

៨- ក្នុងដំណើរការប្រកបអាជីវកម្មរបស់ខ្លួន ត្រូវអនុវត្តតាមច្បាប់ជាធរមានរបស់រដ្ឋ និងប្បញ្ញត្តិនានាតាមការណែនាំរបស់ក្រសួងទេសចរណ៍ និងមិនធ្វើអាជីវកម្មផ្សេងទៀតដោយគ្មានការអនុញ្ញាត។

៩- អនុវត្តតាមច្បាប់ស្តីពីទេសចរណ៍និងបទប្បញ្ញត្តិជាធរមាន ដែលមានក្នុងលក្ខខណ្ឌនានានៃអាជ្ញាបណ្ណទេសចរណ៍។

១០- ត្រូវគោរព និងអនុវត្តឱ្យបានម៉ឺងម៉ាត់តាមច្បាប់ស្តីពីទេសចរណ៍ដូចមានចែងក្នុងមាត្រា ៤៤។

១១- អនុវត្តឱ្យបានម៉ឺងម៉ាត់តាមប្រកាស និងសារាចរណែនាំទាំងឡាយរបស់ក្រសួងទេសចរណ៍ និងច្បាប់ស្តីពីទេសចរណ៍។

១២- អនុវត្តតាមក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈទេសចរណ៍ឱ្យបានល្អ។

១៣- ចូលរួមក្នុងយុទ្ធនាការ "**ទេសចរម្នាក់ ដើមឈើមួយដើម**" ដើម្បីគាំទ្រនិងចូលរួមកាត់បន្ថយផលប៉ះពាល់នៃការកើនឡើងកំដៅលើផែនដី។

១៤- ចូលរួមផ្សព្វផ្សាយដល់បុគ្គលិក និងទេសចរក្នុងការការពារ និងថែរក្សាអនាម័យ បរិស្ថាន និងបង្កើនការយល់ដឹងអំពីវិធានការកាត់បន្ថយការប្រើប្រាស់ថាមពលអគ្គិសនី ទឹក និងគ្រប់គ្រងកាកសំណល់។

១៥- គាំទ្រ និងចូលរួមយុទ្ធនាការឃោសនាផ្សព្វផ្សាយ **កម្ពុជា : ព្រះរាជាណាចក្រអច្ឆរិយៈ** និងចលនាប្រឡងប្រណាំង"**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ**" និងជំរុញចលនាទេសចរក្នុងស្រុកឱ្យមានកំណើនខ្ពស់។

១៦- ចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយថ្លៃកញ្ចប់ទស្សនកិច្ចដើម្បីទាក់ទាញទេសចរ។

១៧- ត្រូវមានផែនការក្នុងការបណ្តុះបណ្តាលបុគ្គលិកបម្រើការងារនូវជំនាញវិជ្ជាជីវៈទេសចរណ៍ និងបដិសណ្ឋារកិច្ច។

១៨- ត្រូវបំពាក់បំពង់ពន្លត់អគ្គីភ័យក្នុងទីស្នាក់ការ និងត្រូវមានច្រកចេញនៅពេលមានអាសន្ន។

១៩- ត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីបរិស្ថានគ្មានផ្សែងបារីដល់អ្នកគ្រប់គ្រង ឬម្ចាស់អាជីវកម្ម សេវាកម្មទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជា។

ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ដែលមិនប្រតិបត្តិតាមគោលការណ៍ណែនាំ លក្ខខណ្ឌខាងលើបណ្តាលឱ្យប៉ះពាល់ដល់នយោបាយទេសចរណ៍ជាតិ ក្រសួងនឹងមានវិធានការសមស្របតាមច្បាប់ជាធរមាន។

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ធិត ចន្ថា**

ចម្លងជូន :
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានពន្ធដារ)
- សាលារាជធានីភ្នំពេញ
" ដើម្បីជូនជ្រាប "
- មន្ទីរទេសចរណ៍រាជធានីភ្នំពេញ " ដើម្បីមុខការ "
- ឯកសារ-កាលប្បវត្តិ

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា
Foreign Trade Bank of Cambodia

ភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៧

**លេខ** : 943-02/5963/2017 លើកទី 01

# លិ ខិ ត ធា នា

អាជ្ញាបណ្ណទេសចរណ៍សម្រាប់ភ្នាក់ងារទេសចរណ៍

(Travel Agent)

**យោង** : ប្រកាសលេខ ០៤១ ប្រក ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ របស់ក្រសួងទេសចរណ៍ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍ និង ភ្នាក់ងារទេសចរណ៍ ។

តាមលិខិតស្នើសុំលេខ : ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៧

របស់ភ្នាក់ងារទេសចរណ៍ : RUTAS (CAMBODIA) TRAVEL CO., LTD

**ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃ កម្ពុជា សូមចេញជូន :**

ភ្នាក់ងារទេសចរណ៍ : RUTAS (CAMBODIA) TRAVEL CO., LTD

នូវលិខិតធានាដែលមានទឹកប្រាក់ចំនួន : ៥,០០០.០០ ដុល្លារអាមេរិក (ប្រាំពាន់ដុល្លារអាមេរិកគត់) ដើម្បីបំពេញបែបបទស្នើសុំអាជ្ញាបណ្ណទេសចរណ៍សម្រាប់ភ្នាក់ងារទេសចរណ៍(Travel Agent) ស្របតាមប្រកាសលេខ ០៤១ ប្រក ចុះថ្ងៃទី១៨ ខែ មករា ឆ្នាំ ២០១៦ របស់ក្រសួងទេសចរណ៍ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍។

លិខិតធានានេះមានសុពលភាពរយៈពេល ០១ឆ្នាំ គិតចាប់ពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៧ រហូតដល់ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៨ ។ ផុតកាលបរិច្ឆេទធនាគារពុំមានការទទួលខុសត្រូវចំពោះលិខិតធានានេះឡើយ។ ប្រតិបត្តិករទេសចរណ៍ជាការីទេសចរណ៍ រឺភ្នាក់ងារទេសចរណ៍ត្រូវមកស្នើសុំអោយធនាគារចេញលិខិតធានាសារជាថ្មីឡើងវិញមុនពេលផុតសុពលភាព ។

**ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃ កម្ពុជា**

**អគ្គនាយក**

FOREIGN TRADE BANK OF CAMBODIA

ឡាយ_រចនា

FTBC 5000

Building No. 33C-D, Street 169, Sangkat Veal Vong, Khan 7Makara, Phnom Penh, Cambodia.
Tel: (855-23) 862 111 / 724 466 / 723 854 / 722 466 / 725 266, Fax: (855-23) 426 108 / 426 410
Email: info@ftbbank.com Website: www. ftbbank.com SWIFT: FTCCKHPP
P.O. Box 114 PNH, Cambodia